# ដំណាំត្រសក់

## ការរៀបចំដីដាំ

- រៀបចំរងទំហំ១ម៉ែត្រ (ត្រូវមានកំពស់ ៣០ សង់ទីម៉ែត្រយ៉ាងតិចនៅរដូវវស្សា)
- ពង្រាយជីលាមកគោស្ងួតរឺជីកំប៉ុស្ត៍ និងជីកែង៧ ពេញរងហើយកាប់ប្រចល់ជាមួយដីអោយសព្វល្អ
- គ្របរងដោយចំបើអោយបានកំរាស់យ៉ាងតិច៥សង់ទីម៉ែត្រ រឺប្រើគំរបដីផ្លាស់ស្ទិក ដើម្បីការពារស្មៅចង្រៃ និងរក្សាសំណើមដី

## ការបណ្តុះកូន

ដើម្បីអោយបានកូនត្រសក់ដែលមានសុខភាពល្អ យើងត្រូវបណ្តុះកូនតាមរបៀបខាងក្រោម:

- រៀបចំកន្ទោងបណ្តុះ (ស្លឹកត្នោត រឺស្លឹកចេក) រឺ ថាសបណ្តុះ
- យកដីមានជីជាតិ(ដីដំបូក)១ភាគ ជីកំប៉ុស្តិ៍ រឺ ជីលាមកគោដែលរលួយ១ភាគ និងផេះអង្កាម១ភាគ លាយជាមួយគ្នាហើយយកទៅលីងអោយក្តៅបំផុត រួចទុកអោយត្រជាក់ទើបដាក់កន្ទោង ។ បើមិនលីងល្បាយដីទេ កូនដំណាំងាយមានជំងឺផ្សិតធ្វើឱ្យលួយបាន ។
- បណ្តុះតែ១គ្រាប់ក្នុងមួយកន្ទោង ដាក់គ្រាប់ផ្តេកនៅពេលបណ្តុះ ត្រូវគ្របសំណាញ់សត្វល្អិត និងធ្វើដំបូលគ្របអំពីស្លឹកដូង ឬ សំណាញ់កាត់ពន្លឺនៅរដូវក្តៅ និងរដូវវស្សាត្រូវធ្វើដំបូលការពារទឹកភ្លៀង ពីព្រោះកូនដំណាំនៅតូចមិនត្រូវការពន្លឺ និងទឹកច្រើនទេ ។
- ស្រោចទឹក១ថ្ងៃមួយដងនៅពេលព្រឹក (បើទុកដីបណ្តុះស្ងួត គ្រាប់មិនអាចដុះបានទេ បើកូនដុះហើយក៏នៅក្រិនដែរ) កូនដំណាំមានសុខភាពល្អ ជួយអោយដំណាំធំលឿន កាត់បន្ថយការបំផ្លាញពីជំងឺ សត្វល្អិត និងទទួលទិន្នផលបានស្មើគ្នា

## ការដាំកូនត្រសក់

- ត្រូវដាក់កូនត្រសក់អោយត្រូវចំពន្លឺថ្ងៃចំនួន ២ រឺ ៣ថ្ងៃមុនដាំ ដើម្បីអោយដើមរឹងមាំល្អហើយផ្សាំនឹងអាកាសធាតុនៅខាងក្រៅ
- កូនត្រសក់អាយុបាន ៥-៧ថ្ងៃ អាចយកដាំបាន (អាស្រ័យតាមការថែទាំកូន)
- ស្រោចទឹកកូនត្រសក់អោយសើមល្មមនៅពេលព្រឹក ទើបយកូនត្រសក់ទៅដាំនៅពេលរសៀល
- យកកូនចេញពីកន្ទោង រឺថាសបណ្តុះដោយប្រុងប្រយ័ត្នបំផុតមិនត្រូវអោយដាច់ឫសកូនត្រសក់ឡើយព្រោះធ្វើអោយកូនត្រសក់អន់បាននៅពេលដាំ
- ត្រូវស្រោចទឹកកូនត្រសក់អោយបានគ្រប់គ្រាន់បន្ទាប់ពីដាំហើយ ជាពិសេសរវាងពី ២-៣ អាទិត្យបន្ទាប់ពីដាំកូនហើយ ។




## ការថែទាំ

- ត្រូវស្រោចទឹកអោយបានគ្រប់គ្រាន់នៅពេលព្រឹក ជៀសវាងស្រោចទឹកច្រើនពេកធ្វើអោយដីសើមជ្រុលនៅពេលថ្ងៃល្ងាច វាអាចបង្កអោយមានបញ្ហាដល់ដំណាំបាន ។
- ត្រូវដោយទ្រើងភ្លាមបន្ទាប់ពីដាំកូនហើយ តែអាចយឺតបំផុតចំនួន៧ថ្ងៃបន្ទាប់ពីដាំកូន ។ បើទុកអោយវាធំទើបដោតទ្រើងធ្វើអោយដាច់ឫសដំណាំ លូតលាស់យឺត ហើយងាយថយទិន្នផល ។
- ត្រូវកាត់ស្លឹកដែលនៅផ្នែកខាងក្រោមក្បែរដីចំនួន១ រឺ ២ សន្លឹកចេញនៅរដូវវស្សា



EAST-WEST SEED

**ការប្រើប្រាស់ជី** ( បើដាក់ជីត្រូវស្រោចទឹក ទើបដំណាំអាចចាប់យកជីបាន)

| ពេលវេលា | ប្រភេទជីប្រើ | កន្លែងដែលត្រូវដាក់ជី |
|---|---|---|
| ដាក់ជីទ្រាប់បាត | **ជី អិន ប៉េ កា (១៥. ១៥.១៥)៧.៥ក្រាម** (១ស្លាបព្រាបាយស្មើ)/ដើម<br>**លាមកសត្វ** ០.៥ គីឡូក្រាម/ដើម | ពង្រាយលើរងហើយកាប់ច្របល់និងដី |
| **ការដាំកូន** | **តែមួយដើម ក្នុងមួយរណ្តៅ** | |
| ២ អាទិត្យបន្ទាប់ពីដាំ | **ជីអ៊ុយរ៉េ** ១០ ក្រាម (១ស្លាបព្រាបាយកំពុង)/ដើម | កប់ជីរាក់ៗ ចំងាយពីគល់កន្លះតឹក |
| ៤ អាទិត្យបន្ទាប់ពីដាំ | **ជី អិន ប៉េ កា (១៥. ១៥.១៥)២.៥ក្រាម** (១ស្លាបព្រាបាយកំពុង)/ដើម<br>**ជីអ៊ុយរ៉េ** ២.៥ក្រាម (១ចុងស្លាបព្រាបាយកំពុង)/ដើម | កប់ជីរាក់ៗ ចំងាយពីគល់១តឹក |
| ៥ អាទិត្យបន្ទាប់ពីដាំ | **ជីប៉ូតាស្យូម** ១.៩ក្រាម (១ចុងស្លាបព្រាបាយស្មើ )/ដើម | កប់ជីរាក់ៗ ចំងាយពីគល់ ១តឹកកន្លះ |
| ៦ អាទិត្យបន្ទាប់ពីដាំ | **ជី អិន ប៉េ កា (១៥. ១៥.១៥)** ២.៥ ក្រាម (១ចុងស្លាបព្រាបាយកំពុង)/ដើម | កប់ជីរាក់ៗ ចំងាយពីគល់ ១តឹកកន្លះ |
| ៨ អាទិត្យបន្ទាប់ពីដាំ | **ជី អិន ប៉េ កា (១៥. ១៥.១៥)** ២.៥ ក្រាម (១ចុងស្លាបព្រាបាយកំពុង)/ដើម | កប់ជីរាក់ៗ ចំងាយពីគល់ ១តឹកកន្លះ |

**ការការពារសត្វល្អិត**

- កុំដាំត្រសក់លើដីដដែលៗនាំកើតមានជំងឺ និងសត្វល្អិតកាន់តែច្រើន ជាហេតុពិបាកកំចាត់វា
- ឧស្សាហ៍ពិនិត្យរកមើលនៅតាមត្រួយត្រសក់ជាពិសេសនៅរដូវក្តៅ ដែលសំបូរដោយពពួកទ្រីបជញ្ជក់ត្រួយត្រសក់ ហើយជាអ្នកចំលងជំងឺវីរុសដល់ត្រសក់នោះមិនអាចព្យាបាលបាន ។

**ជំងឺលឿងស្លឹកៈ** ស្លឹកត្រសក់ចាប់ផ្តើមមានចំនុចអុចៗពណ៌លឿងហើយប្រែជាពណ៌ត្នោត ។ វាកើតពីស្លឹកនៅក្បែរដីវាលទៅស្លឹកផ្នែកខាងលើ ។

- ត្រូវបាញ់ថ្នាំផ្សិត៥ថ្ងៃម្តងនៅរដូវភ្លៀង និង៧ថ្ងៃម្តងនៅរដូវប្រាំង តាំងពីកូនត្រសក់ដុះបានស្លឹក២ដើម្បីការពារជាមុន ។
- បើត្រសក់មានជំងឺផ្សិតហើយ យើងត្រូវកាត់ស្លឹកទាំងនេះចេញសិនមុន និងបាញ់ថ្នាំផ្សិត ។ ស្លឹកនេះត្រូវយកទៅកប់ចោល រឺធ្វើជាជីកំប៉ុស្តបាន ។ កុំទុកស្លឹកនេះនៅក្នុងចំការ វាធ្វើអោយឆ្លងទៅដើមផ្សេងទៀត ។
- សូមបាញ់ថ្នាំផ្សិតនៅពេលម៉ោង៤ទៅម៉ោង៥ល្ងាច ។ ដោយសារផ្សិតជំងឺនៅខាងក្រោមស្លឹក ដូចនេះយើងត្រូវបាញ់ថ្នាំនៅផ្នែកខាងក្រោមស្លឹកឆ្ពោះទៅខាងលើ ។ **កុំបាញ់នៅពេលមេឃជិតធ្លាក់ភ្លៀង មានខ្យល់ និងនៅពេលថ្ងៃត្រង់ ។**

**ប្រការចងចាំ**

- កុំប្រើថ្នាំឈ្មោះកំចាត់សត្វល្អិតនឹងជំងឺដដែលៗ វាធ្វើអោយសត្វល្អិត និងជំងឺមានភាពធន់ទ្រាំជាមួយថ្នាំពិបាកកំចាត់នៅពេលក្រោយ
- កុំប្រើថ្នាំពុលលាយចូលគ្នានៅពេលបាញ់ វាធ្វើអោយថ្នាំគ្មានប្រសិទ្ធិភាព ហើយសត្វល្អិត ដង្កូវរហ័សស៊ាំនឹងថ្នាំ ពិបាកកំចាត់វាពេលក្រោយ ។ ជាពិសេសកុំប្រើថ្នាំដែលមានវណ្ណពណ៌ក្រហម(សញ្ញាក្បាលខ្មោច) វាគ្រោះថ្នាក់ ដល់សុខភាពខ្លាំងណាស់ ។
- ដកដើមត្រសក់ចេញភ្លាមបន្ទាប់ពីបញ្ចប់ប្រមូលផលហើយ ។ កុំទុកដើមដែលឈប់ប្រមូលផលហើយនៅនឹងក្នុងចំការ ។

**ការប្រមូលផល**

- បេះផ្លែត្រសក់នៅពេលព្រឹក និងមិនត្រូវទុកផ្លែដែលបេះហើយអោយត្រូវថ្ងៃក្តៅទេ ។